# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៣

LECTURE 3

## សន្ធិសញ្ញា

TREATY

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ សញ្ញាណទូទៅនៃសន្ធិសញ្ញា
    - និយមន័យ
- ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា
    - លាយលក្ខណ៍អក្សរ
    - ធ្វើឡើងដោយតួអង្គនៃនីតិអន្តរជាតិ
    - បង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ច
    - ស្របច្បាប់អន្តរជាតិ
- ផ្នែកទី៤ លក្ខខណ្ឌសុពលភាពនៃសន្ធិសញ្ញា
    - លក្ខខណ្ឌទម្រង់នៃសុពលភាព
        - ការចរចារ
        - ការចុះហត្ថលេខា
        - ការផ្តល់សច្ចាប័ន

# កម្មវត្ថុនៃមេរៀន

មេរៀនស្តីអំពី សន្និសញ្ញាមានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពីៈ

- អ្វីទៅជាសន្និសញ្ញា
- តើសន្និសញ្ញាមានធាតុផ្សំអ្វីខ្លះ?
- សន្និសញ្ញាមានលក្ខខណ្ឌសុពលភាពអ្វីខ្លះ?
- តើសន្និសញ្ញាត្រូវគោរពនូវលក្ខខណ្ឌអ្វីខ្លះ
- យល់ដឹងពីខដាក់លក្ខខណ្ឌនៃសន្និសញ្ញា
- ស្វែងយល់ពីគុណសម្បត្តិ និងគុណវិប្បត្តិនៃខដាក់លក្ខខណ្ឌ
- យល់ពីអត្ថប្រយោជន៍នៃសន្និសញ្ញា

# ផ្នែកទី១ សេចក្តីផ្តើម

សន្ធិសញ្ញា មិនខុសពីកិច្ចព្រមព្រៀង ឬកិច្ចសន្យាឯកជនទេ គឺត្រូវមានទម្រង់ក្នុងការបង្កើតផ្ទាល់ខ្លួនរបស់វា។ ក្នុងមេរៀននេះ យើងនឹងធ្វើការសិក្សាទៅលើបួនផ្នែកនៃសន្ធិសញ្ញា ដែលក្នុងក្នុងនោះរួមមាន៖ ធាតុផ្សំនៃសន្ធិសញ្ញា លក្ខខណ្ឌសុពលភាពនៃសន្ធិសញ្ញា អានុភាពនៃសន្ធិសញ្ញា និងការផុតរលត់នៃសន្ធិសញ្ញា។

# ផ្នែកទី២ សញ្ញាណទូទៅនៃសន្ធិសញ្ញា

• និយមន័យ

បើយើងនិយាយអំពីសន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវធ្វើឡើងនៅក្នុងទម្រង់ជាលាយលក្ខអក្សរ ហើយនិងត្រូវធ្វើឡើងរវាងតួអង្គនៃនីតិអន្តរជាតិ ដែលក្នុងនោះវាងអាចត្រូវបានធ្វើឡើងរវាងរដ្ឋ និងរដ្ឋ ឬ/និងរវាងរដ្ឋ នឹងអង្គការអន្តរជាតិ ឬ/និងរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ។

# ផ្នែកទី២ សញ្ញាណទូទៅនៃសន្ធិសញ្ញា

- និយមន័យ

អ្នកសិក្សានីតិអន្តរជាតិសាធារណៈ បានឲ្យនិយមន័យសន្ធិសញ្ញាថា គឺជាការសម្តែងនូវឆន្ទៈរបស់តួអង្គនៃនីតិអន្តរជាតិ ហើយការសម្តែងឆន្ទៈទាំងនោះ មានទិសដៅក្នុងការបង្កើតឲ្យមាននូវអានុភាពគតិយុត្តស្របតាមវិធាននៃនីតិអន្តរជាតិ។

# ផ្នែកទី២ សញ្ញាណទូទៅនៃសន្ធិសញ្ញា

• និយមន័យ

យោងតាមសន្ធានុក្រមពាក្យច្បាប់ ដាលូ ២០០៧ បានលើកឡើងថា សន្ធិសញ្ញា គឺជាការព្រមព្រៀងដែលធ្វើឡើងដោយរដ្ឋ ឬ ធ្វើឡើងដោយតួអង្គនៃសង្គមអន្តរជាតិក្នុងទិសដៅបង្កើតឲ្យមានអានុភាពតាមផ្លូវច្បាប់ ក្នុងទំនាក់ទំនងរវាងគ្នានិងគ្នាទៅវិញទៅមក។

# ផ្នែកទី២ សញ្ញាណទូទៅនៃសន្ធិសញ្ញា

សន្ធិសញ្ញាអាចត្រូវបានដាក់ឈ្មោះផ្សេងៗគ្នា អាស្រ័យទៅការចង់បានរបស់ភាគី ដែលចូលរួមក្នុងការបង្កើតសន្ធិសញ្ញាទាំងនោះ (ដូចដែលបានបង្ហាញរួចហើយនៅក្នុងមេរៀនទី២)។

សន្ធិសញ្ញា អាចត្រូវធ្វើឡើងជាកិច្ចព្រមព្រៀងទម្រង់សាមញ្ញ សន្ធិសញ្ញាទ្វេភាគី សញ្ញាពហុភាគីធម្មតា សន្ធិសញ្ញាពហុភាគីទូទៅ ជាអាទិ៍។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

សន្ធិសញ្ញា ត្រូវកើតឡើងដោយមានធាតុផ្សំបួនសំខាន់ៗ ដែលក្នុងនោះរួមមាន៖ សន្ធិសញ្ញាត្រូវតែកើតឡើងពីឯកសារជាលាយលក្ខណ៍អក្សរ ត្រូវតែធ្វើឡើងដោយតួអង្គនៃនីតិអន្តរជាតិ ត្រូវតែបង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ច និងចុងក្រោយសន្ធិសញ្ញានោះតត្រូវតែស្របច្បាប់អន្តរជាតិ។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

• សន្ធិសញ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាទូទៅ សន្ធិសញ្ញាត្រូវមានជាសំណៅឯកសារជាក់ស្តែងដែលក្នុងអាចមានការកត់ត្រាជាសៀវភៅ សត្រាស្លឹករឹត ឬ អាចជាការប្រើនូវមធ្យោបាយផ្សេងទៀតក៏បាន ដូចជាការឆ្លាក់លើផ្ទាំងសិលា ជាអាទិ៍។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ភាគីអាចព្រមព្រៀងគ្នាដើម្បីការបង្កើតកិច្ចព្រមព្រៀង ក្នុងទម្រង់មិនមែនជាលាយលក្ខណ៍អក្សរបាន ប៉ុន្តែកិច្ចព្រមព្រៀងនោះមិនអាចហៅថាជាសន្ធិសញ្ញាបានឡើយ។ ប្រសិនបើកិច្ចព្រមព្រៀងនោះ មិនបានធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរនោះទេ វាគ្រាន់តែជាការសន្យាធម្មតា។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញា ត្រូវធ្វើឡើងដោយតួអង្គនៃនីតិអន្តរជាតិ សន្ធិសញ្ញា ដាច់ត្រូវតែបង្កើតឡើងដោយតួអង្គដែលមានសមត្ថកិច្ចក្នុងការចូលរួមទទួលខុសត្រូវតាមច្បាប់អន្តរជាតិ។ មានការទទួលស្គាល់នូវតួអង្គមួយចំនួនក្នុងការចូលរួមបង្កើតនូវសន្ធិសញ្ញាគឺ រដ្ឋ អង្គការអន្តរជាតិ និងអាជ្ញាធរវ៉ាទីង់។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញា ត្រូវធ្វើឡើងដោយតួអង្គនៃនីតិអន្តរជាតិ ប្រសិនបើតួអង្គណាមួយ បានធ្វើការចុះកិច្ចព្រមព្រៀងជាមួយតួអង្គក្រៅពីនេះ ដូចជានីតិបុគ្គលឯកជន ពេលនោះគេហៅការព្រមព្រៀងនោះថាជា កិច្ចព្រមព្រៀងពហុជាតិ ដែលកិច្ចព្រមព្រៀងប្រភេទនេះ ទាក់ទងការធ្វើសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស និងវាមានអនុភាពដូចកិច្ចសន្យា។

# ផ្នែកទី៣ ឆាត្មផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញា ត្រូវបង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ច

សន្ធិសញ្ញា ត្រូវធ្វើឡើងក្នុងទិសដៅបង្កើតឲ្យមានអនុភាពគតិយុត្ត។ អានុភាពគតិយុត្តនេះ គឺសំដៅការបង្កើតឲ្យមានការទទួលខុសត្រូវ (បង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ច)ចំពោះសកម្មភាពរបស់តួអង្គនៃនីតិអន្តរជាតិ។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញា ត្រូវបង្កើតឲ្យមានសិទ្ធិ និងកាតព្វកិច្ច សូមចង់ចាំថា ការព្រមព្រៀងមួយចំនួនមិនបង្កើតឲ្យមានអានុភាពគតិយុត្តនោះឡើយ ដូចជាកិច្ចព្រមព្រៀងសុភាពបុរស GENTLEMENT AGREEMENTS ដែលកិច្ចព្រមព្រៀងប្រភេទនេះមានចរិកលក្ខណៈនយោបាយច្រើនជាង ពោលពុំបង្កើតឲ្យមានអានុភាពគតិយុត្ត គឺអាស្រ័យឆន្ទៈរបស់ភាគី។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញា ត្រូវតែស្របច្បាប់អន្តរជាតិ

សន្ធិសញ្ញាដែលធ្វើឡើងរវាងរដ្ឋ និងរដ្ឋ ឬ រវាងមួយអង្គការអន្តរជាតិ(អង្គការអន្តររដ្ឋាភិបាល) ត្រូវតែចែងឡើងដោយនីតិអន្តរជាតិ(ត្រូវតែស្របច្បាប់អន្តរជាតិ)។ ភាគីដែលចូលរួមក្នុងការសន្ធិសញ្ញាអាចសម្រេចជ្រើសរើសយកនូវបទដ្ឋានណាមួយក្នុងអនុវត្តរវាងគ្នា ករណីនេះគេហៅថា កិច្ចសន្យា។

# ផ្នែកទី៣ ធាតុផ្សំនៃសន្ធិសញ្ញា

- សន្ធិសញ្ញា ត្រូវតែស្របច្បាប់អន្តរជាតិ

ប្រសិនបើ គេនិយាយថាសន្ធិសញ្ញាត្រូវស្របច្បាប់អន្តរជាតិនោះគេសំដៅដល់ច្បាប់អន្តរជាតិចំនួនពីរគឺ អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីច្បាស់សន្ធិសញ្ញារវាងរដ្ឋ និងរដ្ឋ និងអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៨៦ ស្តីពីច្បាប់សន្ធិសញ្ញារវាងរដ្ឋ និងអង្គការអន្តរជាតិ និង អង្គការអន្តរជាតិ និងអង្គការអន្តរជាតិ។

# ផ្នែកទី៤ លក្ខខណ្ឌសុពលភាពនៃសន្ធិសញ្ញា

សន្ធិសញ្ញាត្រូវបានបង្កើតឡើង ដោយគោរពនូវលក្ខខណ្ឌពីរយ៉ាងគឺ លក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌគ្រឹះនៃសុពលភាព។ នៅក្នុងផ្នែកទី៤នេះ យើងនឹងសិក្សាតែទៅលើលក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញាតែប៉ុណ្ណោះ ហើយនៅក្នុងមេរៀនទី៤ យើងនឹងធ្វើការសិក្សាពីលក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា អានុភាពនៃសន្ធិសញ្ញា និងការផុតរលត់នៃសន្ធិសញ្ញាអន្តរជាតិ។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

នៅក្នុងន័យទូទៅ សន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងដែលធ្វើឡើងដោយឧទ្យោរិក ហើយដែលត្រូវចុះហត្ថលេខាដោយប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬដោយអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការចុះហត្ថលេខាដោយស្របច្បាប់។ ហើយសន្ធិសញ្ញាក្នុងន័យនេះត្រូវឆ្លងកាត់នូវបីដំណាក់កាលគឺ ការចរចារ ការចុះហត្ថលេខា និងការផ្ដល់សច្ចាប័ន។

# លក្ខខណ្ឌតម្រូវនៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ

បុគ្គលដែលមានសមត្ថកិច្ចគ្រប់គ្រាន់ ក្នុងការចូលរួមក្នុងការចរចារ ដើម្បីឈានទៅបង្កើតសន្ធិសញ្ញារួមមានដូចជា នាំយករដ្ឋមន្ត្រី ប្រធានាធិបតី រដ្ឋមន្ត្រីការបរទេស ប្រមុខបេសកកម្មការទូត ហើយក្រៅពីនេះក៏នៅមានបុគ្គលមួយចំនួនទៀតរួមមាន បុណ្ណទូត ដែលទទួលបានសិទ្ធិប្រទាន ជាអាទ៏។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ

ការចរចារក្នុងការបង្កើតសន្ធិសញ្ញាអាចត្រូវបានធ្វើឡើងតាមច្រើនរបៀប គេអាចធ្វើការចរចារតាមផ្លូវការទូត ឬ តាមរយៈការធ្វើសន្និសិទអន្តរជាតិពិសេសណាមួយ ឬ គេអាចធ្វើការចរចារដែលត្រូវបានធ្វើឡើងក្រោមការដឹកនាំសម្របសម្រួលរបស់អង្គការអន្តរជាតិណាមួយ។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ

ភាគីដែលបានចូលរួមក្នុការចរចារ  អាចធ្វើសំណើនៃខ្លឹមសារនៃអត្ថបទនៃសន្ធិសញ្ញា សម្រាប់ការជជែកពិភាក្សា។ ក្នុងករណីដែលភាគីណាមួយ មិនពេញចិត្តចំពោះសេចក្ដីស្នើដែលបានលើកឡើងនោះទេ  គេអាចធ្វើការស្នើសុំឲ្យមានការកែប្រែអត្ថបទដែលបានធ្វើការស្នើមកនោះបាន។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ

ប្រសិន បើមានការឯកភាពទៅលើអត្ថបទដែលបានស្នើឡើងនោះ ជាទូទៅគេធ្វើការអនុម័តដោយការបោះឆ្នោត។ សម្រាប់ការតាក់តែងអត្ថបទនៃសន្ធិសញ្ញានេះផងដែរ គេនិយមប្រើប្រាស់ភាសាផ្លូវការរបស់អង្គការសហប្រជាជាតិ និងភាសារបស់ភាគីនៃសន្ធិសញ្ញានោះ។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ

ក្នុងការតាក់តែងអត្ថបទនៃសន្ធិសញ្ញា ជាទូទៅមានទម្រង់ដូចជា បុព្វកថា តួនៃសន្ធិសញ្ញា និងឧបសម្ព័ន្ធ។

- បុព្វកថា:  គឺជាសេចក្តីផ្តើមនៃអត្ថបទនៃសន្ធិសញ្ញា  ដែលមាននិយាយពីឈ្មោះរបស់ភាគីដែលចូលរួម ហើយក៏មានចែងពីមូលហេតុ និងគោលបំណងនៅក្នុងការបង្កើតសន្ធិសញ្ញាផងដែរ។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ
  - គូនៃសន្ធិសញ្ញាៈ នៅក្នុងផ្នែកនេះគឺមានចែងពីមាត្រាផ្សេងៗនៃសន្ធិសញ្ញា និងរួមទាំងបទបញ្ញត្តិចុងក្រោយផងដែរ។ ក្នុងបទបញ្ញត្តិចុងក្រោយជាទូទៅចែងអំពីការចូលជាធរមាន ការផ្តល់សច្ចាប័ន ការដាក់តម្កល់ វិធានក្នុងការដោះស្រាយវិវាទជាអាទិ៍។

# លក្ខខណ្ឌតម្រូវនៃសុពលភាពនៃសន្ធិសញ្ញា

- ការចរចារ
  - ឧបសម្ព័ន្ធ: ឧបសម្ព័ន្ធនៃសន្ធិសញ្ញាមានអនុភាពសម្រាប់យកទៅអនុវត្តដូចទៅនឹងតួនៃសន្ធិសញ្ញាដែរ។ ជាទូទៅឧបសម្ព័ន្ធនៃសន្ធិសញ្ញា គឺបញ្ញត្តិទាក់ទងទៅនឹងបញ្ហាបច្ចេកទេស ឬក៏អាចបញ្ញត្តិនូវអ្វីដែលនៅមានការខ្វះចន្លោះមិនបានចែងនៅក្នុងមាត្រានានារបស់សន្ធិសញ្ញា ជាអាទិ៍។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចុះហត្ថលេខា

ដំណាក់កាលនៃការចុះហត្ថលេខាលើសន្ធិសញ្ញា គឺជាដំណាក់កាលមួយដ៏សំខាន់ នៅក្នុងដំណើការនៃការបង្កើតសន្ធិសញ្ញា ហើយវាក៏ជាដំណាក់កាលមួយដែលបញ្ជាក់ថា ការបញ្ចប់ការចរចារ ឬក៏អាចនិយាយបានផងដែរថា ដំណាក់កាលនៃការតាក់តែងអត្ថបទនៃសន្ធិសញ្ញាត្រូវបានបញ្ចប់ហើយ។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចុះហត្ថលេខា

ក្រោយពីអត្ថបទនៃសន្ធិសញ្ញាត្រូវបានចុះហត្ថលេខារួចរាល់ហើយ   អត្ថបទនោះមិនអាចធ្វើការកែប្រែបានទៀតឡើយ។ ការចុះទទួលយកអត្ថបទនៃសន្ធិសញ្ញា  គឺជាការផ្តល់នូវភាពស្របច្បាប់ (យថាភាព) នៃអត្ថបទដែលបានព្រាងនោះ។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការចុះហត្ថលេខា

ការចុះហត្ថលេខាទៅលើអត្ថបទនៃសន្ធិសញ្ញា ដែលភាគីបានព្រាងនោះ ពុំមែនមានន័យថាសន្ធិសញ្ញាមានអានុភាពគតិយុត្តនៅឡើយទេ លើកលែងតែសន្ធិសញ្ញាទម្រង់សាមញ្ញ ដែលមិនទាមទារឲ្យមានការផ្តល់សច្ចាប័ន។

# លក្ខខណ្ឌតម្រូវនៃសុពលភាពនៃសន្ធិសញ្ញា

- ការផ្ដល់សច្ចាប័ន

ការផ្ដល់សច្ចាប័ន គឺជាកិច្ចឧទ្បារិកមួយដើម្បីបញ្ជាក់ថា ភាគីបានភ្ជាប់ខ្លួនជាផ្លូវការទៅនឹងសន្ធិសញ្ញាណាមួយ។ គេក៏អាចនិយាយបានផងដែរថា វាជាការផ្ដល់ការយល់ព្រមពីសំណាក់អាជ្ញាធរផ្ទៃក្នុងរបស់រដ្ឋ ហើយនីតិវិធីនៅក្នុងផ្ដល់សច្ចាប័នអាចមានការប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ។

# លក្ខខណ្ឌតម្រូវនៃសុពលភាពនៃសន្ធិសញ្ញា

- ការផ្តល់សច្ចាប័ន

ជាឧទាហរណ៍ សម្រាប់ព្រះរាជាណាចក្រកម្ពុជាការផ្តល់សច្ចាប័ន គឺជាសមត្ថកិច្ចរបស់ព្រះប្រមុខរដ្ឋ ក្រោយពីអត្ថបទនៃសន្ធិសញ្ញានោះត្រូវបានចុះហត្ថលេខាដោយប្រមុខរាជរដ្ឋាភិបាល ហើយក្រោយពីទទួលបានការអនុម័តយល់ព្រមពីសភាទាំងពីរថ្នាក់។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការផ្តល់សច្ចាប័ន

ឯកសារនៃការផ្តល់សច្ចាប័ន ត្រូវប្រគល់ទៅភាគីទាំងឡាយនៃសន្ធិសញ្ញា ហើយលិខិតូបករណ៍នៃការផ្តល់សច្ចាប័ននេះផងដែរត្រូវធ្វើការដាក់តម្កល់នៅអ្នកថែរក្សាសន្ធិសញ្ញាដែលជារដ្ឋ ឬ អង្គការអន្តរជាណាមួយតាមការព្រមព្រៀង។

# លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្ធិសញ្ញា

- ការផ្តល់សច្ចាប័ន

ប្រសិនបើការផ្តល់សច្ចាប័ននោះមិនត្រឹមត្រូវ (ផ្ទុយពីឆន្ទៈពិតរបស់ភាគី) នោះនាំឲ្យសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងទាំងឡាយនោះត្រូវទុកជាមោឃៈ ព្រោះការផ្តល់សច្ចាប័នគឺជាឆន្ទានុសិទ្ធិរបស់តួអង្គនៃនីតិអន្តរជាតិ។ ភាគីទាំងឡាយមានសេរីភាពពេញលេញក្នុងផ្តល់ ឬមិនផ្តល់សច្ចាប័ន។

មេរៀនទី៣ ស្តីពីសន្និសញ្ញាផ្នែកទី១ត្រូវបានបញ្ចប់ យើងនឹងសិក្សាពីសន្និសញ្ញាផ្នែកទី២នៅក្នុងមេរៀនទី៤ លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្និសញ្ញា និងផ្នែកមួយចំនួនទៀត។

សូមអរគុណសម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។